# សុន្ទរកថា

## សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការអគាររដ្ឋបាល

## និងអគារសាលប្រជុំសាលាក្រុង ស្រុកចំនួន៣៤

ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧

- សូមក្រាបថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ
- ឯកឧត្តម លោកជំទាវ សមាជិកព្រឹទ្ធសភា រដ្ឋសភា
- ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ សមាជិក សមាជិកានៃរាជរដ្ឋាភិបាលកម្ពុជា
- ឯកឧត្តម Januar Kakim(យ៉ាន័រ ហាកគីម)តំណាងធនាគារអភិវឌ្ឍន៍អាស៊ី ប្រចាំកម្ពុជា
- ឯកឧត្តមប្រធានក្រុមប្រឹក្សា អភិបាលខេត្តកំពង់ឆ្នាំង ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តកំពង់ធំ ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តតាកែវ ខេត្តកោះកុង និងកំពង់ចាម
- ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាក្រុមប្រឹក្សាខេត្ត និងអភិបាលរងខេត្តកំពង់ឆ្នាំង
- លោកប្រធានក្រុមប្រឹក្សា និងអភិបាលក្រុង ស្រុកទាំង៣៤
- មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធនៃខេត្តកំពង់ឆ្នាំង
- លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស
- លោកតា លោកយាយ និងបងប្អូនជនរួមជាតិ ជាទីមេត្រី!

ថ្ងៃនេះ ខ្ញុំព្រះករុណាខ្ញុំពិតជាមានក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដោយបានមកចូលរួមក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវអគាររដ្ឋបាល និងអគារសាលប្រជុំសាលាក្រុង ស្រុកថ្មីចំនួន ៣៤ ដែលបានរៀបចំប្រារព្ធពិធីសម្ពោធនៅទីតាំងសាលាស្រុកទឹកផុស ខេត្តកំពង់ឆ្នាំងនេះ។

ក្នុងឱកាសដ៏មហោឡារិកនេះ ខ្ញុំសូមសម្តែងនូវក្តីនឹករលឹក និងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ លោកគ្រូ អ្នកគ្រូ លោកយាយ លោកតា ក្មួយៗសិស្សានុសិស្ស និងប្រជាពលរដ្ឋក្នុងស្រុកទឹកផុស ដែលបានចូលរួមយ៉ាងច្រើនកុះករ ព្រមទាំងបានផ្តល់នូវបដិសណ្ឋារកិច្ចយ៉ាងរាក់ទាក់កក់ក្តៅបំផុតចំពោះរូបខ្ញុំ និងគណៈប្រតិភូនៅក្នុងពិធីដ៏នក្ខត្តឫក្សនេះ។

-ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ

-ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក

-បងប្អូនជនរួមជាតិ ជាទីមេត្រី!

គម្រោងសាងសង់សាលាក្រុង ស្រុក ជាសមាសភាគមួយនៃគម្រោងអភិវឌ្ឍន៍សេវាកម្មសាធារណៈ និងការគ្រប់គ្រងហិរញ្ញវត្ថុ តាមបែបវិមជ្ឈការ(DPSFM) ដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី(ADB) មានថវិកាសរុបចំនួន **១៣,៥លានដុល្លារអាមេរិក** និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលចំនួន **១លានដុល្លារអាមេរិក**។ ថវិកាសម្រាប់ការសាងសង់អគាររដ្ឋបាល អគារសាលប្រជុំ និងការបំពាក់សម្ភារសង្ហារឹមឱ្យសាលាក្រុង ស្រុកគោលដៅទាំង ៣៤នេះ ត្រូវបានចំណាយថវិកាប្រមាណ **១១លានដុល្លារអាមេរិក**។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ក្រសួងមហាផ្ទៃ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ដែលជានិច្ចកាលតែងបានជួយគាំទ្រដល់ការស្តារ និងការអភិវឌ្ឍកម្ពុជាលើគ្រប់វិស័យ។ ដោយឡែកក្នុងក្របខ័ណ្ឌកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ បន្ទាប់ពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី១ នាឆ្នាំ២០០២មក ធនាគារអភិវឌ្ឍន៍អាស៊ីបានគាំទ្រដល់កំណែទម្រង់នេះជាបន្តបន្ទាប់ តាមរយៈគម្រោងអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំ សង្កាត់ជំហានទី១ និងជំហានទី២ គម្រោងទ្រទ្រង់ជីវភាពប្រជាជនបឹងទន្លេសាប គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចបឹងទន្លេសាប និងគម្រោងអភិវឌ្ឍន៍សេវាកម្មសាធារណៈ និងការគ្រប់គ្រងហិរញ្ញវត្ថុតាមបែបវិមជ្ឈការ។ គម្រោងទាំងនេះបានចូលរួមចំណែកក្នុងការសាងសង់សាលាឃុំចំនួន ៦៩៧ ការអភិវឌ្ឍប្រព័ន្ធអត្រានុកូលដ្ឋានជាតិ ការអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់ ការបង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចនៅមូលដ្ឋាន ការលើកកម្ពស់ជីវភាពប្រជាពលរដ្ឋតាមរយៈការបង្កើនផលិតភាពកសិកម្ម និងការបង្កើតទុនបង្វិល និងការសាងសង់អគាររដ្ឋបាល និងសាលប្រជុំសាលាស្រុក ក្រុងចំនួន៣៤។

ការគាំទ្រដល់ការសាងសង់អគាររដ្ឋបាល និងសាលប្រជុំនៅសាលាក្រុង ស្រុកទាំង៣៤ នោះ បានអនុវត្តស្របនឹងពេលវេលានៃការអនុវត្តដំណាក់កាលទី២ នៃកម្មវិធីជាតិ

សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលក្នុងដំណាក់កាលនេះ មានគោលបំណងសំខាន់ គឺការផ្តល់សមត្ថភាពជូនរដ្ឋបាលក្រុង ស្រុក ដើម្បីធានាអនុវត្តនូវមុខងារ និងចាត់ចែងធនធានដែលខ្លួនបានទទួលឲ្យមានប្រសិទ្ធភាព សំដៅលើកកម្ពស់ការផ្តល់សេវាជូនប្រជាពលរដ្ឋកាន់តែបានឆ្លើយតប។ ទន្ទឹមនោះ នីតិវិធីនៃការអនុវត្តគម្រោងសាងសង់ បានរួមចំណែកយ៉ាងសំខាន់ដល់រដ្ឋបាលក្រុង ស្រុកគោលដៅនៃគម្រោង អាចទទួលបាននូវមេរៀន បទពិសោធន៍ក្នុងការអនុវត្តគម្រោង ដោយរដ្ឋបាលក្រុង ស្រុកត្រូវបានប្រគល់តួនាទីជាម្ចាស់គណនី ហើយមានភារកិច្ចរៀបចំការធ្វើលទ្ធកម្ម ការត្រួតពិនិត្យក្នុងដំណើរការសាងសង់ ការត្រួតពិនិត្យវាយតម្លៃមុននឹងចេញបញ្ជាចំណាយជូនអ្នកម៉ៅការ ការត្រួតពិនិត្យមុននឹងបញ្ចប់ការដ្ឋានសាងសង់។ ក្នុងការអនុវត្តកិច្ចដំណើរការខាងលើ ក្រុង ស្រុកនីមួយៗបានខិតខំសហការអនុវត្តស្របតាមនីតិវិធីដែលបានកំណត់ ធានាបាននូវតម្លាភាព និងប្រសិទ្ធភាពខ្ពស់ ជាភស្តុតាងគឺសមិទ្ធផលដូចបានឃើញនាពេលនេះ។

នេះជាសមិទ្ធផលយ៉ាងសំខាន់ក្នុងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្រៅពីនេះ នៅមានសមិទ្ធផលសំខាន់ៗជាច្រើនទៀត ដែលខ្ញុំ ព្រះករុណាខ្ញុំ សូមធ្វើការគូសបញ្ជាក់ដូចខាងក្រោម៖

រហូតមកទល់បច្ចុប្បន្ន ពាក់ព័ន្ធនឹងកំណែទម្រង់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រទេសយើងបានធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន៣អាណត្តិ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចំនួន២អាណត្តិរួចមកហើយ ហើយនៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៧ ខាងមុខនេះ យើងនឹងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤។ កិច្ចដំណើរការបោះឆ្នោតទាំងនេះបានប្រព្រឹត្តទៅប្រកបដោយភាពរលូន មានលក្ខណៈសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានសុវត្ថិភាពយ៉ាងល្អប្រសើរ ហើយត្រូវបានទទួលនូវការអបអរសាទរ និងការវាយតម្លៃខ្ពស់ពីសហគមន៍ជាតិ និងអន្តរជាតិ ចំពោះវឌ្ឍនភាពដ៏គួរឱ្យកត់សម្គាល់នៃដំណើរការលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស នៅកម្ពុជា ហើយប្រព័ន្ធគ្រប់គ្រងក៏ត្រូវបានកែសម្រួល ធានាបាននូវភាពជាម្ចាស់ និងប្រសិទ្ធភាពក្នុងការអនុវត្តតួនាទី ភារកិច្ចដែលច្បាប់បានកំណត់។

សមិទ្ធផលដែលសម្រេចបានកន្លងមក គឺបានឆ្លើយតបទៅនឹងគោលបំណងនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការគឺការពង្រឹងលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន ការផ្តល់ឱកាសជូនប្រជាពលរដ្ឋដើម្បីចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត លើកិច្ចការដែលមានផលប៉ះពាល់ដល់ជីវភាពរស់នៅប្រចាំថ្ងៃ និងបានរួមចំណែកជំរុញការអភិវឌ្ឍប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព។

ដើម្បីធានាឱ្យកិច្ចដំណើរការកំណែទម្រង់នេះសម្រេចបានតាមគោលបំណង និងគោលដៅដែលបានគ្រោងទុក រាជរដ្ឋាភិបាលបានដាក់ចេញនូវកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិសម្រាប់រយៈពេល១០ឆ្នាំ (២០១០-២០១៩) អាចនឹងពន្យាពេលដល់ឆ្នាំ២០២០ ដោយបែងចែកជា៣ដំណាក់កាលធំៗសម្រាប់អនុវត្ត។

ដំណាក់កាលទី១ (២០១០-២០១៤) គឺការបង្កើតនូវមូលដ្ឋានគ្រឹះសំខាន់ៗ ដែលធានាដល់ការលើកម្ពស់ស្វ័យភាព ការទទួលខុសត្រូវ និរន្តរភាព និងការបង្កើនប្រសិទ្ធភាពការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានប្រកបដោយតម្លាភាព គណនេយ្យភាព ព្រមទាំងមានការចូលរួមកាន់តែច្រើនឡើងពីសំណាក់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

ដំណាក់កាលទី២ (២០១៥-២០១៧) តម្រូវឱ្យមានកិច្ចខិតខំប្រឹងប្រែងក្នុងការរៀបចំផ្ទេរមុខងារ និងធនធានសមស្រប និងចាំបាច់ពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេសថ្នាក់ក្រុង ស្រុក។ មុខងារដែលនឹងផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាមុខងារដែលបម្រើ និងផ្តល់ផលប្រយោជន៍ជាចម្បងដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន ព្រមជាមួយនឹងការផ្ទេរធនធានដើម្បីបង្កលក្ខណៈឱ្យរដ្ឋបាលក្រុង ស្រុក មានលទ្ធភាពចាប់ផ្តើមអនុវត្តនូវគម្រោងអភិវឌ្ឍជាអាទិភាពក្នុងមូលដ្ឋានរបស់ខ្លួន។

មកដល់បច្ចុប្បន្ន មានក្រសួង ស្ថាប័នចំនួន ១៤ ដែលបានបញ្ចប់នូវការវិភាគមុខងារសម្រាប់ផ្ទេរមកឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងមានក្រសួងមួយចំនួនបានអនុវត្តនូវការផ្ទេរមុខងារជាបណ្តើរៗ។ ជាក់ស្តែង ក្នុងឆ្នាំ២០១៦កន្លងមក ក្រសួងអប់រំ យុវជន និងកីឡាបានផ្ទេរមុខងារការគ្រប់គ្រងការផ្តល់សេវាអប់រំកុមារតូច ការគ្រប់គ្រងការផ្តល់សេវាអប់រំបឋមសិក្សា និងការគ្រប់គ្រងការផ្តល់សេវាអប់រំក្រៅប្រព័ន្ធដល់ក្រុង ស្រុកចំនួន១៤ នៃខេត្តបាត់ដំបង និងមានក្រសួងមួយចំនួនទៀត ដូចជាក្រសួងបរិស្ថាន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសុខាភិបាល។ល។ ព្រមជាមួយនោះ គ.ជ.អ.ប ក៏បានសិក្សា និងលើកសំណើរផ្ទេរមុខងារចំនួន ២៨នៃវិស័យអាទិភាពចំនួន៧ ទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីសុំការពិនិត្យ និងសម្រេចពីសម្តេចតេជោ នាយករដ្ឋមន្ត្រី ក្នុងពេលដ៏ឆាប់ខាងមុខនេះ។

ទន្ទឹមនោះ យើងក៏បានយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេសក្រុង ស្រុក ដើម្បីធានាអនុវត្តប្រសិទ្ធភាពនូវមុខងារដែលបានផ្ទេរមកឲ្យ។ ខ្ញុំសូមជម្រាបជូនថា កន្លងមកនេះយើងមានការសិក្សាមួយចំនួនអំពីស្ថានភាព និងប្រសិទ្ធភាពនៃ

ប្រព័ន្ធគ្រប់គ្រង និងប្រតិបត្តិការការងាររបស់រដ្ឋបាលក្រុង ស្រុក និងការិយាល័យជំនាញនានានៅថ្នាក់ក្រុង ស្រុក ខណ្ឌ ក្នុងនោះខ្ញុំក៏បានដឹកនាំប្រតិភូអន្តរក្រសួងមួយចុះធ្វើការសិក្សាស្វែងយល់អំពីបញ្ហានេះផងដែរនៅតាមក្រុង ស្រុក ខណ្ឌមួយចំនួន។ តាមលទ្ធផលនៃការសិក្សានេះបានបង្ហាញឱ្យឃើញពីភាពចាំបាច់បំផុតក្នុងការពិនិត្យ និងកែលំអឡើងវិញនូវរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ដោយធ្វើការបង្រួមរចនាសម្ព័ន្ធការិយាល័យជំនាញនានានៅថ្នាក់ក្រុង ស្រុក ខណ្ឌទៅតាមចង្កោមវិស័យ ដើម្បីប្រមូលផ្តុំកម្លាំងមន្ត្រីជំនាញក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ព្រមទាំងធ្វើសមាហរណកម្មការិយាល័យជំនាញទាំងនោះ ទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឱ្យស្ថិតក្រោមការដឹកនាំ ការសម្របសម្រួល និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ខណ្ឌ ក្នុងនាមក្រសួង ស្ថាប័ននានានៅថ្នាក់ជាតិ និងក្នុងនាមប្រជាពលរដ្ឋខ្លួននៅមូលដ្ឋាន សំដៅលើកកម្ពស់ការគ្រប់គ្រងតាមគោលការណ៍រដ្ឋបាលឯកភាពនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ឱ្យក្លាយទៅជាស្ថាប័នមានសមត្ថភាព មានលទ្ធភាព និងមានការទទួលខុសត្រូវច្បាស់លាស់ក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន ប្រកបដោយគំនិតផ្តួចផ្តើម និងភាពបត់បែនទៅតាមស្ថានភាពជាក់ស្តែងនៅតាមមូលដ្ឋាននីមួយៗ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលការងារ និងការប្រើប្រាស់ថវិកាសាធារណៈឲ្យចំទិសដៅ និងមានប្រសិទ្ធភាព។

ជារួម កិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការមានការវិវត្តន៍ទៅមុខជាលំដាប់ និងសម្រេចបាននូវសមិទ្ធផលជាច្រើន ពាក់ព័ន្ធនឹងប្រព័ន្ធគ្រប់គ្រងអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយបានជំរុញកំណែទម្រង់នេះឲ្យឈានចូលដំណាក់កាលកាន់តែស៊ីជម្រៅ និងមានភាពសាំញ៉ាំស្មុគស្មាញ នោះគឺការផ្ទេរមុខងារ សិទ្ធិអំណាច និងធនធានពីថ្នាក់ជាតិ ទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

-ព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈ

-ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក

-បងប្អូនជនរួមជាតិជាទីមេត្រី!

ទន្ទឹមនឹងការខិតខំប្រឹងប្រែងជំរុញកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ តាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ក្រសួងមហាផ្ទៃ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងកងកម្លាំងមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ត្រូវខិតខំអនុវត្តឲ្យបានសម្រេចនូវទិសដៅការងាររបស់ខ្លួន សំដៅចូលរួមអនុវត្តដោយជោគជ័យនូវកម្មវិធីកំណែ-

ទម្រង់នានា ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា។ ដើម្បីអនុវត្តសម្រេចនូវទិសដៅជាយុទ្ធសាស្ត្រខាងលើនេះ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ មន្ទីរ អង្គភាពនានា និងកងកម្លាំងមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ និងសូមអំពាវនាវដល់បងប្អូនជនរួមជាតិទាំងអស់ សូមមេត្តាចូលរួមជាមួយរាជរដ្ឋាភិបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ខិតខំរួមគ្នាអនុវត្តនូវកិច្ចការសំខាន់ៗជាអាទិភាពមួយចំនួន ក្នុងនោះរួមមាន៖

១-អាស្រ័យដោយឆ្នាំ២០១៧ និងឆ្នាំ២០១៨ខាងមុខនេះ ប្រទេសកម្ពុជាយើងត្រូវរៀបចំធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងការបោះឆ្នោតជាតិ ហេតុនេះត្រូវពង្រឹងការថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសង្គមឲ្យបានគត់មត់ទូទាំងប្រទេស និងត្រូវផ្តល់ការការពារសន្តិសុខសណ្តាប់ធ្នាប់ក្នុងដំណើរការបោះឆ្នោតទាំងមូល ស្របតាមផែនការរបស់គណៈកម្មការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត និងស្របតាមច្បាប់បោះឆ្នោតតម្រូវ។ ក្នុងការរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ការបង្ការ ការទប់ស្កាត់ និងការបង្រ្កាបបទល្មើស គណៈបញ្ជាការឯកភាពគ្រប់លំដាប់ថ្នាក់ត្រូវយកចិត្តទុកដាក់អនុវត្តជាប្រចាំនូវយុទ្ធនាការបង្រ្កាបបទល្មើសសំខាន់ៗដូចខាងក្រោម៖

+ ការបង្ការ ការទប់ស្កាត់ និងការបង្រ្កាបនូវបទល្មើសប្លន់ ពិសេសសកម្មភាពប្លន់ប្រដាប់អាវុធ ដែលជាបទល្មើសបង្កឲ្យមានការភ័យខ្លាចក្នុងសង្គមទាំងមូល។

+ ការបង្ការ ការទប់ស្កាត់ និងការបង្រ្កាបបទល្មើសគ្រឿងញៀនខុសច្បាប់ តាមរយៈការបំផុសចលនាក្នុងសង្គមទាំងមូល ឲ្យចូលរួមជាមួយអាជ្ញាធរ និងកងកម្លាំងមានសមត្ថកិច្ចក្នុងការអនុវត្តផែនការស្តីពីយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១ រយៈពេល៦ខែ ចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ ដែលបានផ្សព្វផ្សាយកាលពីពេលកន្លងមក។

+ ការបង្ការ ការទប់ស្កាត់ និងការបង្រ្កាបល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទដែលជាប្រភពឬសគល់នៃអំពើចោរកម្ម សកម្មភាពប្លន់ អំពើហិង្សាក្នុងគ្រួសារ...។ល។

+ ការបង្ការ ការទប់ស្កាត់ និងការបង្រ្កាបបទល្មើសព្រៃឈើ និងធនធានធម្មជាតិ សំដៅធានាឲ្យមានការអភិវឌ្ឍប្រកបដោយចីរភាពរយៈពេលវែង សម្រាប់កូនចៅយើងជំនាន់ក្រោយៗទៀត។

ក្នុងការបង្ការ ការទប់ស្កាត់ ការបង្រ្កាបបទល្មើសខាងលើនេះ ត្រូវខិតខំស្រាវជ្រាវរកឲ្យឃើញមេក្លោងដែលជាប្រភពឬសគល់ដែលនាំឲ្យកើតមានបទល្មើសទាំងនេះ។

+ បន្តយុទ្ធនាការពង្រឹងការអនុវត្តច្បាប់ស្តីពីចរាចរជើងគោក ឲ្យបានសកម្មផុលផុសជាប់ជាប្រចាំ សំដៅកាត់បន្ថយជាបន្ថែមទៀតនូវគ្រោះថ្នាក់ចរាចរ ដែលបណ្តាលឲ្យបាត់បង់អាយុជីវិត និងទ្រព្យសម្បត្តិរបស់ប្រជាជន និងធនធាននានាក្នុងសង្គម។

+ គណៈបញ្ជាការឯកភាពគ្រប់លំដាប់ថ្នាក់ត្រូវលុបបំបាត់ឲ្យបានដាច់ខាតនូវប៉ុស្តិ៍ត្រួតពិនិត្យមិនស្របច្បាប់ក្នុងភូមិសាស្ត្ររបស់ខ្លួន និងត្រូវមានការទទួលខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល ករណីកើតមានប៉ុស្តិ៍ត្រួតពិនិត្យមិនស្របច្បាប់ក្នុងភូមិសាស្ត្ររបស់ខ្លួន។ ប៉ុស្តិ៍ត្រួតពិនិត្យមិនស្របច្បាប់ សំដៅទៅលើភ្នាក់ងារមានសមត្ថកិច្ចទាំងឡាយណាដែលដាក់ប៉ុស្តិ៍ត្រួតពិនិត្យ ដែលមិនមានការអនុញ្ញាតត្រឹមត្រូវ ឬភ្នាក់ងារមានសមត្ថកិច្ចទាំងឡាយណាដែលបំពេញការងារនៅប៉ុស្តិ៍ត្រួតពិនិត្យស្របច្បាប់ តែធ្វើសកម្មភាពជំរិតទារប្រាក់ពីប្រជាពលរដ្ឋ និងអាជីវករនានា។

២-បន្តយកចិត្តទុកដាក់កែលម្អការផ្តល់សេវារដ្ឋបាលជូនដល់ប្រជាពលរដ្ឋ អាជីវករ និងអ្នកពាក់ព័ន្ធឲ្យបានឆាប់រហ័ស មានតម្លាភាព និងកាន់តែមានភាពងាយស្រួល ស្របទៅតាមគោលការណ៍ បែបបទ និងនីតិវិធីដែលបានកំណត់។ ក្នុងនោះ ត្រូវចៀសវាងឲ្យបាននូវការយកកម្រៃសេវាក្រៅផ្លូវការឬលើសការកំណត់តាមគ្រប់រូបភាព និងត្រូវទប់ស្កាត់មិនឲ្យមានខ្សែសង្វាក់រដ្ឋបាលតាមបែបការិយាធិបតេយ្យក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋនោះឡើយ។ រដ្ឋបាលខេត្តត្រូវត្រួតពិនិត្យជាប្រចាំអំពីការបិទផ្សាយតារាងកម្រៃសេវា និងរយៈពេលនៃការផ្តល់សេវានៅកន្លែងផ្តល់សេវា និងលើក្តារព័ត៌មានរបស់សាលាខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ និងមន្ទីរ អង្គភាព ការិយាល័យជំនាញ ជូនប្រជាពលរដ្ឋជ្រាប ដើម្បីជំរុញការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការផ្តល់សេវាប្រកបដោយតម្លាភាព។ ទន្ទឹមនេះ រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ មេភូមិ និងជំនួយការមេភូមិទាំងអស់ ត្រូវខិតខំលើកកម្ពស់ការផ្តល់សេវា និងការដោះស្រាយសំណើ ឬសំណូមពរនានារបស់ប្រជាពលរដ្ឋ ប្រកបដោយភាពស្មោះត្រង់ តម្លាភាព ប្រសិទ្ធភាព និងប្រកបដោយសមធម៌។

៣-ត្រូវលើកកម្ពស់ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់មូលនិធិក្រុង ស្រុក ឃុំ សង្កាត់ និងថវិកាគុណប្រយោជន៍ខេត្ត ប្រកបដោយតម្លាភាព គណនេយ្យភាព និងសុចរិតភាព ស្របទៅតាមបែបបទ នីតិវិធីដែលបានកំណត់ ដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាជូនប្រជាពលរដ្ឋ។

៤-ត្រូវបន្តយកចិត្តទុកដាក់សម្របសម្រួល ដោះស្រាយជម្លោះនានានៅមូលដ្ឋាន ពិសេសការសម្របសម្រួលដោះស្រាយវិវាទដីធ្លី ដោយផ្អែកលើគោលការណ៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន មានការចូលរួម ការពិគ្រោះយោបល់ តម្លាភាព ការស្រុះស្រួល ដោយឈរលើមូលដ្ឋាននៃការលើកកម្ពស់សាមគ្គីភាព ការយោគយល់ ការជួយឧបត្ថម្ភគាំទ្រគ្នាទៅវិញទៅមកក្នុងចំណោមប្រជាជន និងសហគមន៍នានានៅគ្រប់មូលដ្ឋាន។ ដើម្បីបង្ការ ទប់ស្កាត់នូវជម្លោះដីធ្លី អាជ្ញាធរមានសមត្ថកិច្ចទាំងអស់មិនត្រូវធ្វើការបញ្ជាក់ទទួលស្គាល់លើឯកសារណាមួយ

ពាក់ព័ន្ធនឹងដីធ្លី អចលនទ្រព្យដែលពុំមានសារតាច្បាស់លាស់ និងអំណះអំណាងខាងផ្លូវច្បាប់គ្រប់គ្រាន់នោះឡើយ។

មុននឹងបញ្ចប់ ជាថ្មីម្តងទៀត ក្នុងនាមរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះធនាគារអភិវឌ្ឍអាស៊ី ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិលនានា ដែលបានគាំទ្រដល់ការស្តារ និងការអភិវឌ្ឍប្រទេសកម្ពុជា ជាពិសេសកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល រួមទាំងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឲ្យដំណើរការដោយរលូន ផ្អែកតាមកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងផែនការអនុវត្តដែលបានកំណត់។

ក្នុងឱកាសដ៏មហោឡារិក អធិកអធមនេះ ក្នុងនាមរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវអគាររដ្ឋបាល និងអគារសាលប្រជុំសាលាក្រុង ស្រុកថ្មីចំនួន៣៤ ដែលបានសាងសង់ក្រោមសមាសភាគ១ នៃគម្រោងអភិវឌ្ឍន៍សេវាកម្មសាធារណៈ និងការគ្រប់គ្រងវិស័យហិរញ្ញវត្ថុតាមបែបវិមជ្ឈការ ចាប់ពីពេលនេះតទៅ និងសូមប្រគេនពរចំពោះព្រះថេរានុថេរៈគ្រប់ព្រះអង្គ សូមជូនពរឯកឧត្តម លោកជំទាវ លោកស្រីអស់លោក និងជនរួមជាតិទាំងអស់ ក្នុងឆ្នាំថ្មី ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ដែលទើបនឹងឆ្លងចូលកាលពីពេលថ្មីៗនេះ សូមមានជោគជ័យ សិរីសួស្តី និងសូមប្រកបដោយពុទ្ធពរទាំង៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

សូមអរគុណ!